00607978

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 22 / 09 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

D411/3/2

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០២/១៩-០៩-២០០៧/អវតក/កសចស (អបជ ៧៦)

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 22 / 09 / 2010
ម៉ោង (Time/Heure): 9:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

ចំពោះមុខ: ចៅក្រម ប្រាក់ គឹមសាន, ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ន៉យ ថុល
ចៅក្រម Catherine MARCHI-UHEL
ចៅក្រម ហួត វុទ្ធី

កាលបរិច្ឆេទ: ថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ២០១០

---

**សាធារណៈ**

## សេចក្តីសម្រេចលើសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំបន្ថែមចំនួនទំព័រ សម្រាប់បណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចអំពីការទទួលយកអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមកពីខេត្តកំពង់ស្ពឺ

---

**សហព្រះរាជអាជ្ញា**
ជា លាង
Andrew CAYLEY

**ជនត្រូវចោទ**
អៀង ធីរិទ្ធ
អៀង សារី
នួន ជា
ខៀវ សំផន

អង្គបុរេជំនុំជម្រះ * PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE * E.C.C.C * C.E.T.C *

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
ហុង គឹមសួន
ឡោ ជុនធី

**សហមេធាវីការពារក្តីជនត្រូវចោទ**
អៀង ធីរិទ្ធ
ផាត់ ពៅស៊ាង

នី ចាន់ឌី
គង់ ពិសី
យុង ផានិត
គីម ម៉េងឃី
ម៉ុច សុវណ្ណារី
Silke STUDZINSKY
Martine JACQUIN
Philippe CANONNE
Elizabeth RABESANRATANA
Olivier BAHOUGNE
ស៊ិន សុវ៉ិន
ជេត វណ្ណលី
ពេជ អង្គ
Lyma NGUYEN
វ៉េន ពៅ
Annie DELAHAIE
Mahdev MOHAN
Marie GUIRAUD
Patrick BAUDOIN
Fabienne TRUSSES-NAPROUS
Ferdinand DJAMMEN-NZEPA
Christine MARTINEAU
Laure DESFORGES
Isabelle DURAND
Emmanuel ALTIT
Emmanuel JACOMY
Barnabe NEKUIE
Daniel LOSQ
Julien RIVET
Pascal AUBOIN
Francoise GAUTRY

Diana ELLIS

អៀង សារី
អាង ឧត្តម
Michael G. KARNAVAS

នួន ជា
សុន អរុណ
Michel PESTMAN
Victor KOPPE

ខៀវ សំផន
ស ស្ទូវាន
Jacques VERGES
Philippe GRECIANO

E.C.C.C. * CHAMBRE PRELIMINAIRE * PRE-TRIAL CHAMBER

០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ៧៦)

លេខ /No. D411/3/2

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("**អ.វ.ត.ក**") បានទទួល "សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី សុំបន្ថែមចំនួនទំព័រសម្រាប់បណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចអំពីការទទួលយកអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមកពីខេត្តកំពង់ស្ពឺ" ("សំណើសុំ") ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១០។

១. នៅក្នុងសំណើសុំរបស់ខ្លួន សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំឱ្យអង្គបុរេជំនុំជម្រះ៖

១) អនុវត្តឆន្ទានុសិទ្ធិក្នុងការយល់ព្រមឱ្យមានការបន្ថែមចំនួនទំព័រដែលបានកំណត់សម្រាប់ដាក់ចម្លើយតបដែលមានចំនួនប្រហែល ១៣០ទំព័រជាភាសាខ្មែរ ដោយមិនរាប់បញ្ចូលទំព័រចំណងជើង ទំព័រឯកសារយោង និងទំព័រឧបសម្ព័ន្ធនោះទេ ដើម្បីជួយឱ្យសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី អាចដាក់បណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធនឹងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើម បណ្តឹងរដ្ឋប្បវេណីចំនួន ១២៦នាក់។

២) ផ្តល់ចម្លើយតបទៅនឹងសំណើសុំនេះផ្អែកតាមលក្ខណៈបន្ទាន់នៃបណ្តឹងឧទ្ធរណ៍ដែលនឹងមកដល់នាពេលខាងមុខនេះ ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន។

២. អង្គបុរេជំនុំជម្រះសង្កេតឃើញថា សំណើរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសុំបន្ថែមចំនួនទំព័រដែលបានកំណត់ ត្រូវបានធ្វើឡើង ដោយសារតែកាលៈទេសៈពិសេសដូចតទៅ ៖១) បណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធនឹងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីជាច្រើននាក់(១២៦)។ ២) វានឹងបណ្តាលឱ្យមានភាពអយុត្តិធម៌ចំពោះអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីប្រសិនបើអ្នកដាក់ពាក្យសុំត្រូវបានបង្ខំឱ្យកាត់បន្ថយខ្លឹមសារអង្គហេតុ និងខ្លឹមសារផ្នែកច្បាប់ជាច្រើនដែលបណ្តឹងឧទ្ធរណ៍យកធ្វើជាសំអាង ដោយសារតែការកំណត់ឱ្យសរសេរត្រឹមតែ ៣០ទំព័រ។ និង ៣) វាជាឧត្តមប្រយោជន៍នៃភាពត្រឹមត្រូវ យុត្តិធម៌ និងប្រសិទ្ធភាពផ្នែកនីតិវិធី ការគ្រប់គ្រងឯកសារ និងការពិនិត្យលើពាក្យបណ្តឹងឧទ្ធរណ៍ ដែលរៀបចំសវនាការសម្រេចលើបណ្តឹងឧទ្ធរណ៍



អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRÉLIMINAIRE

ចំនួន ១២៦ ដែលរួមបញ្ចូលគ្នានៅក្នុងបណ្តឹងឧទ្ធរណ៍រួមតែមួយ ជាជាងឱ្យអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដាក់បណ្តឹងឧទ្ធរណ៍ដាច់ដោយឡែកពីគ្នា។

៣. អង្គបុរេជំនុំជម្រះពិចារណាឃើញថា មូលហេតុដែលសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងដើម្បីបន្ថែមចំនួនទំព័រដែលបានកំណត់ បង្ហាញនូវកាលៈទេសៈពិសេសដែលស្ថិតនៅក្នុងអត្ថន័យនៃពាក្យដែលបានប្រើប្រាស់នៅក្នុងមាត្រា ៥.៤ នៃសេចក្តីណែនាំអនុវត្ត។

**ហេតុដូច្នេះ អង្គបុរេជំនុំជម្រះ÷**

**យល់ព្រមតាម** សំណើសុំរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសុំបន្ថែមចំនួនទំព័រដែលបានកំណត់ដើម្បីដាក់បណ្តឹងឧទ្ធរណ៍។

ភ្នំពេញ ថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ២០១០

ប្រធានអង្គបុរេជំនុំជម្រះ

ប្រាក់ គឹមសាន